# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុនស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក ជាមួយតំណាងកម្មករ
# និង
# តំណាងកម្មករ និយោជិត

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១០ និង ៣០នាទី ព្រឹក នៅក្នុងក្រុមហ៊ុន ស៊ីអិនឌីហ្វ្រី អិនធើណេសិនណល (ខេអេច) ឯ.ក មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និងតំណាងកម្មករនិយោជិត ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់ កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ន នៅក្នុងរោងចក្រថា ដោយសារតែក្រុមហ៊ុនយើងខ្វះការបញ្ជាទិញ ដែលជាហេតុមិនអាចអោយសង្វាក់ផលិតកម្ម ដំណើរការបាន។ ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិតមួយចំនួន រយៈពេលចំនួន ៣២ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០។ ហើយនៅក្នុងអំឡុងពេលព្យួរការងារនេះ កម្មករ និយោជិត បានឯកភាពទទួលការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់ឈ្នួល ៣០ ដុល្លា អាមេរិច ក្នុងមួយខែ សម្រាប់កម្មករ និយោជិតម្នាក់ៗ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ១១:00 នាទី ព្រឹក នាថ្ងៃខែឆ្នាំដដែល ដោយភាគីទាំងសង់ខាងមានភាពស្និតស្នាល និងយោគយល់គ្នាក្រោមស្មារតីទទួល និងសហការគ្នាយ៉ាងរលូន។

ថ្ងៃព្រហស្បតិ៍ ០១រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

កំពង់ស្ពឺ, ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២០

**នាយកក្រុមហ៊ុន**

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

ហ៊ុន លាងឈា    ឈុំ រីណា    ហ៊ន ស្រីពៅ    ទ្បេង ណារី

អ៊ឹម កុសល    ផល តុលា    នឿន សុបិណ្ឌ    នា ណារ៉